# អនុក្រឹត្យ

# ស្តីពី

# ការកិច្ច  និងរចនាសម្ព័ន្ធទៅ

# នៃកងរាជអាវុធហត្ថ

**រាជរដ្ឋាភិបាលកម្ពុជា**

**អនុក្រឹត្យ/៧៧ អនក្រ/២១ ធ្នូ ១៩៩៤/ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង សហអគ្គមេបញ្ជាការនៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិ និងក្រុមប្រឹក្សាអ្នកច្បាប់ អមនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១.-**

កងរាជអាវុធហត្ថ ដែលគ្រប់គ្រងដោយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ២.-**

នាយករដ្ឋមន្ត្រី ជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅ ។ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ អ្នកទទួលខុសត្រូវ លើផ្នែករដ្ឋបាលទូទៅ និងជាអ្នកផ្តល់សំភារៈ និងថវិកា សំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ ។ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ មានភារៈគ្រប់គ្រងសំដៅហ្វឹកហ្វឺន កសាងរៀបចំ កងរាជអាវុធហត្ថ អោយរីកចំរើន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រងតួនាទី និងភារកិច្ចរបស់ខ្លួន ។

**មាត្រា ៣.-**

កងរាជអាវុធហត្ថ ជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានស្វ័យភាព ក្នុងកិច្ចអនុវត្តច្បាប់ កងរាជអាវុធហត្ថ មានសកម្មភាពផ្នែក ប៉ូលីសដែលមានឧបនិស្ស័យជាអន្តរក្រសួង ។ សមត្ថកិច្ចកងរាជអាវុធហត្ថ ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ទៅលើពលរដ្ឋស៊ីវិល ព្រមទាំងទៅលើយោធា ក្នុងជួរកងទ័ពផង ។

**មាត្រា ៤.-**

កងរាជអាវុធហត្ថមានភារកិច្ច :

ក-រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល :

- រក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- រ៉ាប់រងអោយមានការគោរពច្បាប់ និងបទបញ្ជាទាំងឡាយ
- ផ្តល់ពតិមាន និងជួយសង្គ្រោះពលរដ្ឋស៊ីវិល

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថ អនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

ខ-រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ :

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និងទោសកម្ម
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភស្តុតាងផ្សេងៗ
- ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាច ពីចៅក្រមស៊ើបសួរ

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ អង្គការអយ្យការ និងអាជ្ញាធរតុលាការមានសមត្ថកិច្ច ។

គ-បំពេញបេសកម្ម ដែលមានលក្ខណៈពិសេសខាងយោធា :

- ទទួលបន្ទុករក្សាសុវត្ថិភាព និងបំពេញតួនាទី ជាកងកិត្តិយស ជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និងអាជ្ញាធរជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ។
- ការពារទីតាំងយោធា
- កិច្ចការប៉ូលីសយោធា នៅក្នុង និងក្រៅទីតាំងកងទ័ព

ក្នុងក្របខ័ណ្ឌ នៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជា របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរយោធាមានសមត្ថកិច្ច ។

ឃ-ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់ ។

**មាត្រា ៥.-**

កងរាជអាវុធហត្ថ អាចនឹងទទួលបេសកម្មផ្នែកប៉ូលីស ពិសេសបន្ថែមដោយអនុលោមតាមអនុក្រឹត្យក្នុងបច្ចាកាល ។

**មាត្រា ៦.-**

រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុហត្ថមាន :

- អធិការដ្ឋានកងរាជអាវុធហត្ថ ទទួលខុសត្រូវដោយអធិការមួយរូប និងអធិការរងមួយរូប ។

- បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ទទួលខុសត្រូវដោយមេបញ្ជាការមួយរូប និងមេបញ្ជាការរងមួយរូប ។

**មាត្រា ៧.-**

អធិការដ្ឋានកងរាជអាវុធហត្ថ ។

អធិការ និងអធិការរងកងរាជអាវុធហត្ថមានភារកិច្ចបំពេញបេសកម្មត្រួតពិនិត្យ សិក្សា និងផ្តល់ពតិមាន ។ អធិការ និងអធិការរងកងរាជអាវុធហត្ថ ត្រូវស្ថិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ ដែលជាអ្នកកំណត់បេសកម្ម ។

អធិការ និងអធិការរងកងរាជអាវុធហត្ថ ជាទីប្រឹក្សាអចិន្ត្រៃយ៍របស់នាយករដ្ឋមន្ត្រី ។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ ត្រូវផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រី នូវគំរោងស្តីពីអនាគត ផ្នែករចនាសម្ព័ន្ធ និងមុខងាររបស់កងរាជអាវុធហត្ថ ។ អធិការកងរាជអាវុធហត្ថ តោងតែតាមពិនិត្យមើលដោយផ្ទាល់នូវកិច្ចប្រតិបត្តិ ការងារ និងការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថ អោយសមស្របតាមក្បួនច្បាប់ ។

**មាត្រា ៨.-**

បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ។

បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយមេបញ្ជាការ ថ្នាក់ឧត្តមសេនីយ៍ និងមេបញ្ជាការរងមួយរូបមានភារកិច្ច :

- ចងក្រងបទបញ្ញត្តិការងារទូទៅ និងតាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួង ពាក់ព័ន្ធដូចជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ជាដើម ។
- ផ្តល់ពតិមានដល់នាយករដ្ឋមន្ត្រី អំពីមធ្យោបាយគ្រប់បែបយ៉ាង ដែលមានភាពបំរើការងារបាន ។
- ដោះស្រាយកែសម្រួល ចំពោះបញ្ហាទាក់ទងក្នុងការរៀបចំផ្នែករដ្ឋបាល និងដំណើរការប្រព្រឹត្តទៅ របស់កងរាជអាវុធហត្ថ ។

ឋិតនៅក្រោមបញ្ជា របស់មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថមាន :

- សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ
- កងរាជអាវុធហត្ថផ្ទៃប្រទេស
- កងរាជអាវុធហត្ថចល័ត
- តម្រួតយោធា ។

**មាត្រា ៩.-**

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ :

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ ត្រូវទទួលបន្ទុក :

- រៀបចំកម្មវិធីបង្រៀន
- ហ្វឹកហ្វឺនបុគ្គលិក
- ត្រួតពិនិត្យការហ្វឹកហ្វឺន

- រៀបរៀង និងចងក្រងឯកសារសំរាប់បង្រៀន
- ធ្វើសំណើរទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថ នូវសំភារៈជាចាំបាច់ សំរាប់ដំណើរការសិក្សា អោយមានប្រសិទ្ធភាព ។

**មាត្រា ១០.-**

កងរាជអាវុធហត្ថផ្ទៃប្រទេស :

កងរាជអាវុធហត្ថផ្ទៃប្រទេស ដែលដាក់អោយអនុវត្តការងារ នៅពេញផ្ទៃព្រះរាជាណាចក្រកម្ពុជារហូតទៅដល់ថ្នាក់ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកម្ម របស់កងរាជអាវុធហត្ថ ដែលមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ។

សមត្ថកិច្ចនៃកងរាជអាវុធហត្ថផ្ទៃប្រទេស អនុវត្តទៅលើពលរដ្ឋស៊ីវិល និងយោធា ។

**មាត្រា ១១.-**

កងរាជអាវុធហត្ថចល័ត :

កងរាជអាវុធហត្ថចល័ត ជាកងកំលាំងសំរាប់រ៉ាប់រងអោយមានសណ្តាប់ធ្នាប់ និងប្រយុទ្ធប្រឆាំងនឹងក្រុមប្រដាប់អាវុធខុសច្បាប់ ។ កងរាជអាវុធហត្ថចល័ត អនុវត្តការងារពេញផ្ទៃប្រទេស តាមការស្នើសុំពី កងរាជអាវុធហត្ថផ្ទៃប្រទេស ឬតាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ចផ្នែករដ្ឋបាល ឬតុលាការ ។

កងរាជអាវុធហត្ថចល័តត្រូវត្រៀមខ្លួនជានិច្ច សំរាប់បន្ថែមកំលាំងក្នុងពេលខ្លីបំផុត ទៅជួយកងឯកភាពនៃកងរាជ-អាវុធហត្ថផ្ទៃប្រទេស ។

**មាត្រា ១២.-**

តម្រួតយោធា :

តម្រួតយោធា គឺជាកងកំលាំងមួយ នៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះទៅធ្វើការផ្ទាល់ជាមួយនឹងកងទ័ពទាំងបីប្រភេទ នៃកងយោធពលខេមរភូមិន្ទ ។ តម្រួតយោធា បំពេញបេសកម្មនេះក្រោមបញ្ជាអាជ្ញាធរ ដូចមានចែងក្នុងវគ្គ"គ" នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៣.-**

អធិការ ឬមេបញ្ជាការកងរាជអាវុធហត្ថ អាចស្នើបង្កើន នូវអង្គភាពឯកទេសផ្សេងៗ ទៀតដើម្បីប្រសិទ្ធភាពការងារ ក្នុងកាលៈទេសៈចាំបាច់ ។

**មាត្រា ១៤.-**

នាយករដ្ឋមន្ត្រីសម្រេចកំណត់ភារកិច្ចចំនួនជាក់ស្តែង និងការតែងតាំងក្នុងការរៀបចំស្ថាប័នលើសំណើពីមេបញ្ជាការ និងអធិការកងរាជអាវុធហត្ថ ដែលបានពិភាក្សាប្តូរយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

**មាត្រា ១៥.-**

អនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ឆ្នាំ ១៩៩៤ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុ

ក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងគ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណប្ញទ្ធិ ហ៊ុន សែន